# សុន្ទរកថារបស់លោក Nicolas Michel អគ្គលេខាធិការរង អ.ស.ប និងជាតំណាងពិសេសរបស់ ឯកឧត្តម កូហ្វី អាណាន់

(សុន្ទរកថានេះត្រូវបានធ្វើឡើង នៅល្ងាចថ្ងៃចន្ទ ទី៣ ខែកក្កដា ឆ្នាំ២០០៦ នៅក្នុងឱកាសលាងសាយភោជន៍ បន្ទាប់ពីពិធីស្បថរបស់មន្ត្រីតុលាការនៅសណ្ឋាគារឡឺរ៉ូយ៉ាល់)

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានក្រុមការងារ!

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ពេលវេលាសម្រាប់យុត្តិធម៌បានមកដល់ហើយ។

យើងទាំងអស់គ្នាជ្រាបហើយថា យុត្តិធម៌ព្រហ្មទណ្ឌតែមួយមិនអាចជួសជុល ឬផ្តល់នូវការពន្យល់ឲ្យបានពេញលេញសម្រាប់ឧក្រិដ្ឋកម្មនិងភាពអយុត្តិធម៌ដែលបានប្រព្រឹត្តនៅក្នុងអំឡុងរយៈកាលកម្ពុជាប្រជាធិបតេយ្យនោះបានទេ។ ជាពិសេស ក្រោយពីពេលវេលាបានកន្លងផុតជាច្រើនឆ្នាំ។ ប៉ុន្តែ តើនេះមានន័យថាយើងត្រូវទុកឲ្យអំពើឃោរឃៅដែលត្រូវបានប្រព្រឹត្តឡើងជាប្រព័ន្ធក្នុងទ្រង់ទ្រាយធំបែបនេះមិនទទួលការផ្តន្ទាទោសឬ? តើយើងត្រូវទទួលយកនិទណ្ឌភាពទាំងស្រុងឬ? កម្ពុជាសម្រេចមិនធ្វើដូច្នេះឡើយ។ ផ្ទុយទៅវិញ កម្ពុជាបានជ្រើសរើសផ្លូវ យុត្តិធម៌ ផ្លូវសន្តិភាព ពោលគឺ ជាសន្តិភាពដែលមានលក្ខណៈឋិតថេរនិងមាននិរន្តរភាព។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយបានឈានមកដល់នៅថ្ងៃនេះ នៅលើវិថីឆ្ពោះទៅរកយុត្តិធម៌ និងសន្តិភាពប្រកបដោយនិរន្តរភាព។ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្នុងការតំណាងឲ្យលោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងការពាំនាំនូវគារវកិច្ចដ៏ស្និទ្ធស្នាល និងពាំនាំសារដឹងគុណ និងលើកទឹកចិត្តដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់។

ជាកិច្ចចាប់ផ្តើម ខ្ញុំសូមសម្តែងនូវការដឹងគុណចំពោះអាជ្ញាធរ អង្គការ និងបុគ្គលទាំងឡាយដែលបានផ្តល់ការគាំទ្រដ៏សំខាន់ដល់ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើង ដែលបានផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឲ្យអង្គជំនុំជម្រះនេះមានដំណើរការ។ សារនេះគឺផ្ញើជូនជាដំបូងដល់អាជ្ញាធរកម្ពុជា ដែលឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន គឺជាតំណាងនៅក្នុងវេលាល្ងាចនេះ ជាពិសេសក្នុងឋានៈឯកឧត្តម ជា

ប្រធានក្រុមការងារ។ ការចូលរួមដ៏សកម្មរបស់អាជ្ញាធរជាតិបាននិងនៅតែមានសារៈសំខាន់ក្នុងការធ្វើឱ្យដំណើរការជាប្រវត្តិសាស្ត្រនេះបានទៅមុខ។

សូមផ្ញើជូននូវសារដឹងគុណជាពិសេសដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ចៅក្រមនិងព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ។ ការងារដ៏សំខាន់ស្ថិតនៅលើស្មារបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី។ ក្នុងកម្រិតដែលថាកត្តាខាងក្រៅនឹងអនុញ្ញាតឱ្យឯកឧត្តម លោកជំទាវ អស់លោក លោកស្រីអនុវត្តមុខងាររបស់ខ្លួនដោយពេញលេញ ដូចដែលខ្ញុំរំពឹងទុកនោះ កម្ពុជានិងសហគមន៍អន្តរជាតិពឹងលើឯកឧត្តម លោកជំទាវ អស់លោក លោកស្រីក្នុងការបំពេញគោលបំណងរបស់អង្គជំនុំជម្រះវិសាមញ្ញ។ កម្ពុជានិងសហគមន៍អន្តរជាតិពឹងលើទេពកោសល្យនិងគុណភាពរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ពោលគឺៈ វិជ្ជាជីវៈ អនាគតិ និងឯករាជ្យភាពរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី។ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនឹងត្រូវបានគាំទ្រដោយបុគ្គលិកប្រកបដោយទេពកោសល្យ និងភក្តីភាព ដែលបានស្តែងឱ្យឃើញរួចមកហើយតាមរយៈការខិតខំប្រឹងប្រែងបំពេញការងាររបស់ពួកគាត់។ ពួកគាត់ក៏សមនឹងទទួលការកោតសរសើរដោយស្មោះពីសំណាក់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីផងដែរ។

សារដឹងគុណពិសេសមួយទៀតផ្ញើជូនរដ្ឋជាសមាជិកដែលបានផ្តល់ការគាំទ្រដល់អង្គជំនុំជម្រះវិសាមញ្ញ ជាពិសេស "ក្រុមប្រទេសជាមិត្តរបស់ អ.វ.ត.ក"។ រដ្ឋទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតយុត្តាធិការថ្មីនេះ។ ប៉ុន្តែនេះគ្រាន់តែជាការចាប់ផ្តើមដំបូងប៉ុណ្ណោះ ហើយការយកចិត្តទុកដាក់ប្រុងប្រយ័ត្ន និងការគាំទ្រឥតងាករេរបស់រដ្ឋទាំងនេះគឺនៅតែមានសារៈសំខាន់។ អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលស្គាល់និងកោតសរសើរតួនាទីនេះ និងគូសបញ្ជាក់ពីសារៈសំខាន់នៅពេលនេះជាងពេលណាៗទាំងអស់។ លោក អគ្គលេខាធិការ ថ្លែងអំណរគុណរដ្ឋនីមួយៗដែលបាននាំយកជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញ និងរំលេចដោយការកោតសរសើរ ចំពោះការណ៍ដែលថាប្រទេសបារាំងនិងជប៉ុនបានទទួលជាសហប្រធាននៃក្រុមប្រទេសជាមិត្តរបស់អ.វ.ត.ក។

សារដឹងគុណមួយទៀតសូមផ្ញើជូនស្ថាប័នមិនមែនរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិ។ ខ្ញុំជឿជាក់ថា ស្ថាប័ននិងអង្គការទាំងនេះដែលមានបុគ្គលិកប្រកបដោយទឹកចិត្តនិងភាពស្មោះស្ម័គ្រ មានទេពកោសល្យ និងសេចក្តីក្លាហាន នឹងបន្តដើរតួនាទីដ៏មុឺងម៉ាត់របស់ខ្លួន។ វាកាន់តែមានលក្ខណៈច្បាស់ថាថ្ងៃនេះ

គ្មានអាជ្ញាធរសាធារណៈណាដែលអាចប្រឈមនិងផ្តល់ដំណោះស្រាយគ្រប់ជ្រុងជ្រោយចំពោះការប្រឈម នានាដែលយើងទាំងអស់គ្នាកំពុងជួបប្រទះដោយគ្មានការចូលរួមពេញលេញពីសំណាក់សង្គមស៊ីវិលឡើយ។

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកសារព័ត៌មានទាំងអស់។ ព័ត៌មាននិងការធ្វើសេចក្តីរាយការណ៍របស់ពួក គាត់ត្រូវតែបន្តប្រុងប្រយ័ត្នទៅលើការពិតនិងការពារឯករាជ្យភាពរបស់ខ្លួន ដែលជាភាពចាំបាច់នៃករណីកិច្ចសា ស្ត្រវិជ្ជាជីវៈរបស់ពួកគាត់។ ការធ្វើសេចក្តីរាយការណ៍បែបនេះនឹងអនុញ្ញាតឲ្យសង្គមកម្ពុជាទាំងមូលចូលរួមក្នុង ការវិវត្តផ្នែកតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញ និងក្លាយជាផ្នែកមួយដ៏សំខាន់នៃដំណើរការនេះ ដោយចាក់គ្រឹះ កាន់តែជ្រៅសម្រាប់យុត្តិធម៌និងសន្តិភាព។

សារដែលខ្ញុំមានកិត្តិយសសូមពាំនាំមកជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនាល្ងាចនេះក៏គឺ ជាសារនៃការលើកទឹកចិត្តនិងការគាំទ្រផងដែរ។ យើងដឹងថាការលំបាក និងការប្រឈមនឹងកើតមានឡើង។ នឹងមានការពេញចិត្តយ៉ាងខ្លាំង ហើយក៏នឹងមានមន្ទិលផងដែរ។ គឺនៅពេលនោះហើយដែលចៅក្រម ព្រះរាជ អាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវមានគុណភាព៖ ភាពរឹងមាំខាងសីលធម៌ និងការតាំងចិត្តឈានទៅសម្រេច គោលដៅរបស់ខ្លួន។ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បានចូលរួមដោយផ្ទាល់ជាមួយសហកម្មជា ប្រវត្តិសាស្ត្រមួយ។ តាមពិតឯកឧត្តម លោកជំទាវ អស់លោក លោកស្រីគឺជាតួអង្គរបស់សហកម្មនេះ។ឯក ឧត្តម លោកជំទាវ អស់លោក លោកស្រីកំពុងសរសេរអំពីខ្លួនឯងទៅក្នុងប្រវត្តិសាស្ត្រ។ ប្រវត្តិសាស្ត្រកម្ពុជាក៏ ដូចជា ប្រវត្តិសាស្ត្រសហគមន៍អន្តរជាតិបានចូលរួមកាន់តែច្រើនឡើងៗ នៅទីនេះនិងនៅកន្លែងផ្សេងទៀត ក្នុង ការបង្កើតវប្បធម៌នៃគណនេយ្យភាពដើម្បីជំនួសវប្បធម៌និទណ្ឌភាពដ៏គួរឲ្យខ្លាច។ តាងនាមអគ្គលេខាធិការ ខ្ញុំ សូមប្រសិទ្ធពរឯកឧត្តម លោកជំទាវ អស់លោក លោកស្រីមានកម្លាំងមាំមួន មានសេចក្តីក្លាហាន គតិបណ្ឌិត ភាពអត់ធ្មត់តិចតួច និងពេញចិត្តចំពោះកិច្ចការដែលបានសម្រេចដ៏ល្អ។

ខ្ញុំអាចនឹងមិនលើកឡើងនូវសារដ៏សំខាន់មួយនាពេលល្ងាចនេះ ប្រសិនបើខ្ញុំមិនបាននិយាយទៅកាន់ប្រជា ជនកម្ពុជាដោយផ្ទាល់។ ប្រទេសរបស់អ្នក មិត្តភក្តិកម្ពុជារបស់ខ្ញុំ បានរស់នៅក្នុងសោកនាដកម្ម ដែលអាចរាប់ បានគិតជាថ្ងៃ ខែ និងឆ្នាំ។ ប្រជាជនជាច្រើនបានបាត់បង់ជីវិត។ ប្រជាជនជាច្រើនបានទទួលរងការឈឺចាប់ និង បន្តទទួលរងការឈឺចាប់ពីការបាត់បង់អ្នកជាទីស្រលាញ់របស់ខ្លួន និងពីអំពើឃោរឃៅដែលពួកគាត់បានទទួលរង។ អ្នកកំពុងស្រេកឃ្លានការពិត យុត្តិធម៌ និងការផ្សះផ្សា។ អ្នកកំពុងស្រេកឃ្លានសន្តិភាព។ អ្នកចង់ធ្វើដំណើរទៅមុខ

ទាំងអស់គ្នាដើម្បីមានអនាគតប្រសើរជាងនេះ។ ថ្ងៃនេះ ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលរបស់អ្នក សហគមន៍អន្តរជាតិឆ្លើយតបនឹងសេចក្តីអំពាវនាវរបស់អ្នកនិងផ្តល់ជូនអ្នកនូវការគាំទ្រដ៏ពេញទំហឹង។

ចូរយើងធ្វើការទាំងអស់គ្នាដើម្បីឲ្យអង្គជំនុំជម្រះទទួលបានជោគជ័យ។ ភាពជោគជ័យនេះនឹងក្លាយជាសញ្ញាមួយនៅក្នុងតំបន់បញ្ជាក់ប្រាប់ថាវប្បធម៌និទណ្ឌភាពដ៏គួរឲ្យខ្លាចពិតជាកំពុងត្រូវបានជំនួសដោយវប្បធម៌នៃគណនេយ្យភាព។ វាក៏អាចបន្សល់ទុកជូនកម្ពុជានូវកេរតំណែលវិជ្ជមានមួយចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការពង្រឹងនីតិរដ្ឋ។ នៅចុងបញ្ចប់ ប្រសិនបើយើងទទួលបានជោគជ័យក្នុងការសម្រេចគោលដៅរបស់យើង នោះប្រជាជនកម្ពុជានឹងសម្រេចបានព្រឹត្តិការណ៍មួយលើវិថីឆ្ពោះទៅរកយុត្តិធម៌ សន្តិភាព សេរីភាព និងសុខមាលភាព។

នេះគឺជាអ្វីដែលខ្ញុំបួងសួងសម្រាប់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អស់ពីដួងចិត្ត។

សូមអរគុណ!